UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia/កម្ពុជា

**បន្ទាប់ពីសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ អង្គការសហប្រជាជាតិបាននិយាយអំពីការការពារសិទ្ធិទទួលបានលំនៅឋានសមរម្យសម្រាប់សហគមន៍ដែលបានតាំងទីលំនៅថ្មី**

ភ្នំពេញថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២ – សិទ្ធិទទួលបានលំនៅឋានសមរម្យនៅក្នុងប្រទេសកម្ពុជាមិនត្រូវបានគោរព ការពារ និងបំពេញអោយបានពេញលេញទេពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅ និងការតាំងទីលំនៅថ្មីរបស់សហគមន៍ ប៉ុន្តែគោលការណ៍ណែនាំថ្មីស្តីពីការតាំងទីលំនៅថ្មី មានគោលបំណងជួយដល់រាជរដ្ឋាភិបាលក្នុងការផ្តល់នូវស្តង់ដាលំនៅឋានអោយមានភាពកាន់តែប្រសើរឡើងដល់សហគមន៍ដែលត្រូវបានបណ្តេញចេញ។

ជាផ្នែកមួយនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួនជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជួយដល់ស្ថាប័នរដ្ឋក្នុងការគោរព និងការពារសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) បានផ្សព្វផ្សាយនូវរបាយការណ៍ស្តីពីសិទ្ធិមនុស្ស និងការតាំងទីលំនៅថ្មីដែលក្នុងនោះក៏មានគោលការណ៍ណែនាំ និងអនុសាសន៍ដើម្បីបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានកំណត់ក្នុងលក្ខណៈរួម។

លោកស្រី **ផរលីន ថាម៉េស៊ីស** អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានស្វាគមន៍របាយការណ៍នេះនៅក្នុងសុន្ទរកថាបើកកម្មវិធីរបស់លោកស្រី នៃការចាប់ផ្តើមផ្សព្វផ្សាយរបាយការណ៍ស្តីពីការសិក្សានេះកាលពីម្សិលមិញ។

លោកស្រីបានមានប្រសាសន៍ថា "អនុសាសន៍ដែលបានលើកឡើងនៅក្នុងរបាយការណ៍ គឺស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ហើយស្របគ្នានឹងការសន្យារបស់រាជរដ្ឋាភិបាលដែលបានធ្វើឡើងក្នុងអំឡុងពេលត្រួតពិនិត្យឡើងវិញជាសកលរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១៩ ដើម្បីធានាថាវិវាទដីធ្លី ការបណ្តេញចេញ និងការផ្លាស់ទីលំនៅដែលមិនទាន់សម្រេចទាំងអស់ ត្រូវបានដោះស្រាយដោយយុត្តិធម៌ តម្លាភាព ការចរចា និងមធ្យោបាយផ្តល់សំណងគ្រប់គ្រាន់"។

"ការសិក្សាពីស្ថានភាពសិទ្ធិមនុស្សរបស់សហគមន៍ដែលរស់នៅក្នុងតំបន់តាំងទីលំនៅថ្មីក្នុងប្រទេសកម្ពុជា" ដែលបានផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងប្រទេសស៊ុយអែតបានរកឃើញថា នៅកន្លែងតាំងទីលំនៅថ្មីជាច្រើនគឺស្ថិតនៅក្នុងទីតាំងដែលបង្កការលំបាកសម្រាប់ប្រជាជនដែលរងផលប៉ះពាល់ក្នុងការទទួលបានសិទ្ធិមនុស្សផ្សេងទៀតរបស់ពួកគេ ឧទាហរណ៍ដូចជាក្នុងករណីដែលសេវាអប់រំ និងសេវាថែទាំសុខភាពស្ថិតនៅឆ្ងាយពីទីតាំង។ គណៈកម្មាធិការអន្តរក្រសួងអាចធានាថា សិទ្ធិទាំងអស់ត្រូវបានការពារ និងត្រូវបានចាត់ទុកថាចាំបាច់ក្នុងករណីដែលមានការតាំងទីលំនៅថ្មី។

របាយការណ៍នេះធ្វើឡើងដោយសំអាងលើការពិសោធន៍ជាក់ស្តែង និងយ៉ាងទូលំទូលាយរយៈពេលពីរឆ្នាំ ដោយពិនិត្យមើលស្ថានភាពសិទ្ធិមនុស្សនៅក្នុងតំបន់តាំងទីលំនៅថ្មីចំនួន១៧ នៅក្នុងរាជធានីភ្នំពេញ និងខេត្តចំនួនប្រាំបី។

របាយការណ៍នេះបានបង្ហាញពីនិន្នាការគួរឱ្យព្រួយបារម្ភដែលសហគមន៍ដែលត្រូវបានបណ្តេញចេញ ត្រូវបានបញ្ជូនទៅកន្លែងតាំងលំនៅថ្មីមុនពេលដែលហេដ្ឋារចនាសម្ព័ន្ធ និងសេវាមូលដ្ឋាន ជាពិសេសការផ្គត់ផ្គង់ទឹកចល័ត អនាម័យ សន្តិសុខស្បៀង ផ្លូវថ្នល់ អគ្គិសនី សេវាសុខភាព និងសេវាអប់រំ ត្រូវបានបង្កើតឡើងនៅកន្លែងតាំងទីលំនៅថ្មី។

តំណាងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លោក **ប្រាឌីប វ៉ាគ្លេ** បាននិយាយនៅក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ថា "អាជ្ញាធរពាក់ព័ន្ធគួរតែធានាថា មុនពេលតាំងទីលំនៅថ្មី សេវាមូលដ្ឋានត្រូវបានបង្កើតឡើងនៅកន្លែងតាំងទីលំនៅថ្មី"។ របាយការណ៍ក៏បានរកឃើញថា គ្រួសារដែលបានតាំងទីលំនៅថ្មីមិនត្រូវបានផ្តល់ការជូនដំណឹងគ្រប់គ្រាន់អំពីការផ្លាស់ទីលំនៅ និងមិនត្រូវបានផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំផែនការ និងរៀបចំសម្រាប់ការផ្លាស់ប្តូរទីលំនៅ។

ប្រធានការិយាល័យនៃស្ថានទូតស៊ុយអែតប្រចាំរាជធានីភ្នំពេញ លោកស្រី **ខាមីឡា អូតតូសាន់** បានមានប្រសាសន៍ថាសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍នេះត្រូវបានកំណត់ពេលវេលាយ៉ាងល្អ។

"របាយការណ៍នេះផ្តល់នូវការរកឃើញក្នុងន័យស្ថាបនាដល់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយកង្វល់សិទ្ធិមនុស្សទាក់ទងនឹងការតាំងលំនៅថ្មី។ របាយការណ៍នេះក៏បានបំពេញបន្ថែមនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលក្នុងនោះរួមមានគោលដៅទី១១ ស្តីពីទីក្រុង និងសហគមន៍ប្រកបដោយចីរភាព ដែលរដ្ឋជាសមាជិកអង្គការសហប្រជាជាតិទាំងអស់យល់ព្រមធានាឱ្យមានលទ្ធភាពទទួលបានលំនៅឋាន និងសេវាមូលដ្ឋានគ្រប់គ្រាន់ សុវត្ថិភាព និងភាពអាចលៃលកបានត្រឹមឆ្នាំ២០៣០។"

អ្នកការពារជួរមុខ និងអង្គការសង្គមស៊ីវិលមួយចំនួនបានមានវត្តមាននៅក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ រួមទាំងនាយិកាប្រតិបត្តិមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោកស្រី **ចក់ សុភាព** ដែលលោកស្រីបាននិយាយថារបាយការណ៍នេះបានបង្ហាញពីទំនាក់ទំនងសំខាន់ៗរវាងសិទ្ធិទទួលបានលំនៅឋានសមរម្យ និងសិទ្ធិមនុស្សជាមូលដ្ឋានផ្សេងទៀត។

"[មានភាពប្រាស្រ័យគ្នាយ៉ាងច្បាស់លាស់] រវាងសិទ្ធិទទួលបានលំនៅឋានសមរម្យ និងការទទួលបានសិទ្ធិមនុស្សផ្សេងទៀត រួមទាំងសិទ្ធិទទួលបានការអប់រំ សិទ្ធិមានការងារធ្វើ និងសិទ្ធិទទួលបានស្តង់ដាសុខភាពខ្ពស់បំផុត"។ លោកស្រីបានកត់សម្គាល់ពីបញ្ហាប្រឈមពិសេសដែលស្ត្រី និងជនជាតិដើមភាគតិចជួបប្រទះ។

ច្បាប់ដែលមានស្រាប់ គោលនយោបាយ និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាលទាក់ទងនឹងលំនៅឋានសមរម្យ ផ្តល់នូវការការពារកម្រិតជាក់លាក់មួយអំពីការបណ្តេញចេញដោយបង្ខំ និងការតាំងទីលំនៅថ្មី។ ទោះបីជាយ៉ាងណាក៏ដោយ មកទល់នឹងពេលនេះ មិនទាន់មានគោលការណ៍ណែនាំជាតិដែលមានស្រាប់ស្តីពីការតាំងទីលំនៅថ្មីនៅឡើយទេ នៅពេលដែលការផ្លាស់ប្តូរទីតាំងដែលលទ្ធផលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច និងគម្រោងអភិវឌ្ឍន៍ដែលផ្តល់មូលនិធិដោយឯកជន។

នាយកប្រចាំប្រទេសនៃអង្គការផីពផលអ៊ីននីត លោក **ឡូកាស ឡោបេ** បានមានប្រសាសន៍ថា "ភាពទន់ខ្សោយស្ថិតនៅលើការអនុវត្តដែលពាក់ព័ន្ធជាចម្បងទៅនឹងសមត្ថភាពរបស់ស្ថាប័ន និងកង្វះការសម្របសម្រួលរវាងក្រសួងផ្សេងៗ ដើម្បីអភិវឌ្ឍ និងអនុវត្តវិធានការគោលនយោបាយជាក់ស្តែង"។

"ប្រសិនបើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការតាំងទីលំនៅថ្មីត្រូវបានអនុម័ត ដំណោះស្រាយនឹងអាចដោះស្រាយបាន"។

ការិយាល័យ OHCHR ផ្តល់អនុសាសន៍ទៅដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីអនុម័ត និងអនុវត្តសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការតាំងទីលំនៅថ្មី ដែលបានភ្ជាប់ជាមួយនឹងការសិក្សា និងសម្រាប់ការបង្កើតគណៈកម្មាធិការអន្តរក្រសួង ដើម្បីអនុញ្ញាតឱ្យស្ថានភាពសិទ្ធិមនុស្ស និងការតាំងទីលំនៅថ្មីត្រូវបានដោះស្រាយតាមរយៈវិធីសាស្រ្តរបស់រាជរដ្ឋាភិបាលទាំងមូល។

លោក **វ៉ាត្តេ** បានមានប្រសាសន៍ថា "ការិយាល័យ OHCHR ប្រចាំនៅកម្ពុជាជឿជាក់ថា ការអនុម័ត និងការអនុវត្តគោលការណ៍ណែនាំទាំងនេះ អាចនឹងរួមចំណែកដល់ភាពរីករាយរបស់ប្រជាពលរដ្ឋ ក្រុម និង សហគមន៍ទាំងអស់ចំពោះសិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យមួយ"។

ចប់

សម្រាប់ការសាកសួរ និងសំណូមពរប្រព័ន្ធផ្សព្វផ្សាយ សូមទំនាក់ទំនង៖
អាម៉ែនដា ហ្វីសសឺ +៨៥៥ (0) ១៧ ៨៧៥ ៥៩២ /fisher4@un.org